# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....៦៣ អនក្រ.....

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការសិក្សា និងវាយតំលៃលើការសុំបូមស្តារព្រែកកោះប៉ោ និងមាត់ព្រែកពាមក្រសោប របស់ខេត្តកោះកុង

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ .-**

បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការសិក្សា និងវាយតំលៃលើការសុំបូមស្តារព្រែកកោះប៉ោ និងមាត់ព្រែកពាមក្រសោប របស់ខេត្តកោះកុង ដែលមានសមាសភាពដូចខាង ក្រោម ÷

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | យុទ្ធ | ភូថង | អភិបាលខេត្តកោះកុង | ជាប្រធាន |
| ២-លោក | សុខ | ឡេង | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាអនុប្រធាន |
| ៣-ឯកឧត្តម | មេង | សាខុន | តំណាងក្រសួងធនធានទឹកនិងឧតុនិយម | ជាអនុប្រធាន |
| ៤-លោក | ស៊ុន | គីមស៊្រុន | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-លោក | អ៊ឹង | ទ្រី | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |

៦-លោក **ឆាយ ថាន់ធន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៧-លោក **ខួន គង់** តំណាងក្រសួងបរិស្ថាន ជាសមាជិក

៨-លោក **ខៀវ អាន** តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

**ប្រការ ២ .-**

គណៈកម្មការខាងលើនេះ មានសិទ្ធិ និងភារកិច្ចដូចតទៅ ÷

-ធ្វើការសិក្សា និងវាយតំលៃ :

- បរិមាណទំហំដែលត្រូវជីក
- ចំនួនភាគរយនៃដីល្បាប់ និងដីខ្សាច់ដែលលាយគ្នា
- ការរាំងស្ទះមុខទឹក
- ការចាក់សំណល់អាចម៍ដី
- វិភាគរ៉ែ ដែលនៅក្នុងដីជីកចេញ
- ការវាយតំលៃ EIA
- ប៉ាន់ស្មានតំលៃជីក ប្រៀបធៀបនឹងតំលៃលក់ខ្សាច់
- បច្ចេកទេសនៃការជីក

-ត្រូវធ្វើរបាយការណ៍ អំពីសកម្មភាព និងលទ្ធផលការងាររបស់គណៈកម្មការ ប្រគល់មកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទីស្តីការគណៈរដ្ឋមន្ត្រីរៀបចំដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។

-គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តកោះកុង ។

**ប្រការ ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួនក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៣
-ឯកសារ-កាលប្បវត្តិ